Jo. Ann Albers

# <u>ក្រមសីលធម៌ និង ជំបូន្មានវិជ្ជាជីវៈ នៃសមាគមនាយកសារពត៌មានវិទ្យុ និង ទូរទស្សន៍កម្ពុជា</u>

សមាគមន៍នាយកសារពត៌មានវិទ្យុនិទូរទស្សន៍ កម្ពុជា ដោយមានបំណងថែរក្សានូវស្តង់ដារកំរិតខ្ពស់បំផុតសំរាប់ វិជ្ជាជិវៈ សារពត៌មាន អេឡិកត្រូនីក និង ដើម្បីជំរុញឱ្យមានការយល់ដឹងជាសាធារណៈនិងការជឿរជាក់ លើសារពត៌មាន តាមរលកធាតុអាកាស និង ដើម្បីពង្រឹងលើគោលការណ៍ស្តីអំពីសេរីភាពសារពត៌មាន ក្នុងការប្រមូល និង ផ្សាយពត៌មាន បានឯកភាពគ្នាបង្កើតនូវក្រមសីលធម៌ និង ក្រមទូន្មានសំរាប់វិជ្ជាជិវៈនេះឡើង ។

សេចក្តីបន្ថែមដែលបានស្នើរៈ ក្រមសីលធម៌ នេះជាផ្នែកមួយដែល ចំលងមកពីក្រមសីលធម៌ ដែលបានអនុម័តដោយ RTNDA នៅក្រុង Monneapolis នៃរដ្ឋ Minnesota នៅថ្ងៃទី14 ខែ កញ្ញា ឆ្នាំ 2000 ។

## <u>បុព្វកថា</u>

អ្នកសារពត៌មានអាជីពវិទ្យុ និង ទុរទស្សន៍ ត្រូវធ្វើយ៉ាងណាឱ្យក្លាយខ្លួនឱ្យគួរជាទីទុកចិត្តរបស់សាធារណៈជន ដោយស្វះស្វែង រកការណ៍ពិតដើម្បីរាយការណ៍ពត៌មានពិត ដោយយុតិធម៌ សុច្ចរីតស្មោះត្រង់ និង ឯករាជ្យ ហើយត្រូវទទួលខុសត្រូវ ចំពោះ អំពើរបស់ខ្លួន ។

## <u>ជំនឿទុកចិត្តរបស់សាធារណជនៈ</u>

អ្នកសារពត៌មានអេឡិកត្រូនិកអាជីព ត្រូវទទួលស្គាល់ថា ខ្លួនមានកាតព្វកិច្ចជាចំបងបំផុត ចំពោះសាធារណជន ។

## <u>អ្នកសារពត៌មានអាជីពវិទ្យុ និង ទុរទស្សន៍ត្រូវតែៈ</u>

- យល់ថាការព្យាយាមណាមួយ ក្រៅតែពីការបម្រើ សាធារណៈជននោះនឹងនាំឱ្យខូចអន្តរាយដល់ការពិត និង ទំនុក ចិត្តអំពីសាធរណៈ ជនមកលើខ្លួន ។
- ទទួលស្គាល់ថាក្នុងការបម្រើផលប្រយោជន៍សាធារណៈ បង្កើតឱ្យមានជាកាតព្វកិច្ចមួយ ដែលឆ្លុះបញ្ចាំងនូវលក្ខណៈចំរុះ ពិសេសរបស់សង្គម ហើយត្រូវការពារ ទល់នឹងការព្យាយាមសម្រាលបញ្ហា ទាំងឡាយ ឱ្យសាមញ្ញ

ហួសហេតុពេក ព្រមទាំង ផ្តល់ពត៏មាន ក្នុងទ្រង់ទ្រាយ ពេញលេញគ្រប់សព្វដើម្បី ដើម្បីញ៉ាំងឱ្យសាធារណៈជន អាចយល់បាន និងធ្វើសេចក្តីសំរេច ចិត្តផ្សេងៗ បាន ដោយច្បាស់លាស់ ។

- ប្រយុទ្ធតស៊ូដើម្បីធានាឱ្យបានថាកិច្ចការសាធារណៈត្រូវ បានធ្វើឡើងនៅក្នុងទីសាធារណៈ ។
- អ្នកសារពត៏មាន វិទ្យុ និង ទុរទស្សន៍ មិនត្រូវបរិហារកេរ្តិ៍ អ្នកដ៏ទៃ ។

## ការណ៍ពិត

អ្នកសារពត៏មានអាជីពវិទ្យុ និង ទុរទស្សន៍ ត្រូវតែខិតខំពុះពារស្វែងរកការពិត ហើយបង្ហាញ (ផ្សព្វផ្សាយ) ដំណឹងរបស់ខ្លួន ឱ្យច្បាស់លាស់ ត្រឹមត្រូវ ស្របតាមបរិបទ និងទូលំទូលាយ ពេញលេញតាមតែអាចធ្វើកើត ។
(Cambodian#8 incorporated in this)

## អ្នកសារពត៏មានអាជីពវិទ្យុ និង ទូរទស្សន៍ ត្រូវតែៈ

- ស្វែងរកការពិតជាប្រចាំ ចៀសវាងការបំភ្លៃពត៏មាន ដែលអាចធ្វើឱ្យខ្លឹមសារសំខាន់របស់ព្រឹត្តិការណ៍នានា មានភាព ស្រពិចស្រពិល មិនច្បាស់លាស់។
- លាតត្រដាងច្បាស់លាស់ នូវប្រភពដើមនៃពត៏មាន ហើយបញ្ជាក់ច្បាស់នូវរាល់រឿងរ៉ាវដែលខ្លួនទទួលបានពោល គឺ បានមកពីណា ទីណា ។
- ការពារប្រភពរបស់ខ្លួន ។

## អ្នកសារពត៏មានអាជីពវិទ្យុ និង ទូរទស្សន៍ មិនត្រូវៈ

- ~~រិះគន់ ឬ បន្តុះបង្អាប់ប្រទេសជាតិឯង~~ [illegible]
- រាយការណ៍ពត៏មានណាមួយ ដែលខ្លួនដឹងថាមិនពិត
- បំភ័ន្តរូបភាព និងសំលេង តាមរបៀបណាមួយដែលអាចឱ្យអ្នកស្តាប់យល់ច្រឡំ។
- បង្ហាញ-ផ្សាយ-រូបភាព រឺសំលេងទាំងឡាយណាដែលត្រូវបានយកមកប្រើឡើងវិញ ដោយមិនឱ្យសាធារណជនដឹង
- លួចស្នាដៃអ្នកដ៏ទៃ ~~(Cambodia #4)~~

## ភាពយុត្តិធម៌

អ្នកសារពត៌មានអាជីពវិទ្យុ និង ទូរទស្សន៍ ត្រូវបង្ហាញដំណឹងរបស់ខ្លួនដល់សាធារណជនដោយភាព យុតិធម៌ និងមិនលំអៀង ទៅខាងណា ដោយសង្កត់ធ្ងន់ទៅលើសារសំខាន់ និងភាពពាក់ព័ន្ធរបស់វា និង រួមមានប្រភព គ្រប់ភាគីដែលពាក់ព័ន្ធ ។ ~~(Incorporates Cambodia #7)~~

**អ្នកសារពត៌មានអាជីពវិទ្យុ និង ទូរទស្សន៍ ត្រូវតែ:**

- យកចិត្តទុកដាក់គោរពដល់ប្រធាន-ប្រធានបទ-ទាំងឡាយនៃដំណឹងផ្សព្វផ្សាយរបស់ខ្លួន ប្រកបដោយភាពថ្លៃថ្នូរ ដោយបង្ហាញឱ្យឃើញជាពិសេសនូវសមានចិត្ត អាណិតមេត្តា ដល់ជនរងគ្រោះពីឧក្រិដ្ឋកម្មណាមួយ ឬ សោកនាដកម្មណាមួយ។
- មានការប្រុងប្រយ័ត្នជាពិសេស នៅពេលណាដែលកុមារមានជាប់ពាក់ព័ន្ធ នៅក្នុងរឿង ហើយផ្តល់កិច្ចការពារដល់កុមារ ច្រើនជាងការពារមនុស្សពេញវ័យ។
- ស្វះស្វែងយល់អំពីលក្ខណៈពិសេសដោយឡែកៗ របស់សហគមន៍ ហើយរាយការណ៍ពត៌មានជូនសាធារណជន ដោយមិនលំអៀង និងមិនប្រកាន់និន្នាការ។
- បង្ហាញនូវលក្ខណៈចម្រុះ សំបូរបែប នៃមតិ យោបល់ ផ្សេងៗ នៅក្នុងសង្គម។
- បង្ហាញសេចក្តីរាយការណ៍វិភាគពត៌មាន ដោយផ្អែកលើទស្សនវិស័យវិជ្ជាជីវៈ មិនលំអៀង។
- គោរពសិទ្ធិទទួលការវិនិច្ឆ័យទោស ដោយយុត្តិធម៌ ។

**អ្នកសារពត៌មានអាជីពវិទ្យុ និង ទូរទស្សន៍ មិនត្រូវ:**

- វាយប្រហារ ឬ ទិតៀនបុគ្គលណាមួយជាអន្តរជាតិ ។ ~~(Cambodian#9)~~

**ភាពសុច្ចរិត ទៀងត្រង់:**

អ្នកសារពត៌មានអាជីពវិទ្យុ និង ទូរទស្សន៍ ត្រូវបង្ហាញ-ផ្សាយ-ដំណឹងរបស់ខ្លួន ដោយក្តីសុច្ចរិត ទៀងត្រង់ ចៀសវាងនូវ ទំនាស់ផលប្រយោជន៍ណាមួយ ទោះដោយភាពជាក់ច្បាស់ក្តី ដោយការប្រមើលមើលឃើញក្តី និងត្រូវគោរពដល់ភាពថ្លៃថ្នូរ និងបញ្ញាញាណរបស់អ្នកស្តាប់ ព្រមទាំងប្រធាន-ប្រធានបទ-នៃដំណឹង។

**អ្នកសារពត៌មានអាជីពវិទ្យុ និង ទូរទស្សន៍ គប្បី:**

- ប្រាប់អត្តសញ្ញាណប្រភពពត៌មាន នៅពេលណាដែលអាចធ្វើបាន។ ការលាក់ប្រភពពត៌មាន គប្បីប្រើប្រាស់តែនៅពេលណា ដែលរឿងនោះប្រាកដជាបម្រើផលប្រយោជន៍សាធារណៈ ក្នុងការប្រមូលពត៌មាននិងពាំនាំពត៌មានសំខាន់ៗឬក៏នៅពេលដែល អ្នកផ្តល់ពត៌មាននោះអាចទទួលគ្រោះថ្នាក់។ អ្នកកាសែតត្រូវការពារឱ្យបាននូវប្រភព ពត៌មានសំងាត់ ។ ~~(Cambodian#1)~~
- បញ្ជាក់ឱ្យច្បាស់ នូវទស្សនៈ និងអត្ថាធិប្បាយ ។
- ការពារកុំឱ្យមានការយកពត៌មានផ្សព្វផ្សាយបន្ថែម អំពីព្រឹត្តិការណ៍ រឺ បុគ្គលនានា ដែលពុំមានអ្វីជួយ ធ្វើឱ្យពត៌មាននោះមាន ន័យបន្ថែមជាដុំកំភួន។ ដំណឹងត្រូវផ្សារភ្ជាប់ទៅនឹងបរិបទជាក់ស្តែង រឺធ្វើយ៉ាងណា ជួយឱ្យសាធារណជនបានយល់ដឹងអំពីរឿង នោះកាន់តែច្បាស់ថែមទៀត។
- ចៀសវាងកុំទាក់ទងជាមួយនឹងអ្នកដែលចូលរួមក្នុងសភាពការណ៍ហឹង្សា នៅពេលដែលសភាពការណ៍នោះកំពុងតែវិវត្តន៍ ទៅមុខ។
- ប្រើប្រាស់បច្ចេកទេសយកពត៌មាន ដែលមិនសមគួរដូចជាលាក់ម៉ាស៊ីនថត និងមីក្រូហ្វូនជាដើម លុះត្រាតែពុំមានវិធីណា ផ្សេង ដើម្បីទទួលបាននូវដំណឹងដែលមានសារសំខាន់ចំពោះសាធារណជន និងលុះត្រា តែបច្ចេកទេសនោះត្រូវបានពន្យល់ ប្រាប់ដល់សាធារណជន ឱ្យបានដឹងផង។
- យកដំណឹងពីអង្គការសារពត៌មានដ៏ទៃៗទៀតមកផ្សាយបាន លុះត្រាតែមានការអនុញ្ញាត។

## **អ្នកសារពត៌មានអាជីព វិទ្យុ និង ទូរទស្សន៍ មិនគប្បី:**

- ផ្តល់ប្រាក់ឱ្យប្រភពពត៌មានទាំងឡាយណា ដែលមានផលប្រយោជន៍បង្កប់នៅក្នុងរឿងនោះ ។ (Cambodian#5)
- ទទួលអំណោយ ការយកចិត្តយកថ្លើម រឺការទូទាត់ប្រាក់កាសពីសំណាក់នរណាមួយ ដែលព្យាយាមជះ ឥទ្ធិពលលើដំណឹង ។
- ចូលរួមនៅក្នុងសកម្មភាពទាំងឡាយណាដែលអាច ធ្វើឱ្យប៉ះពាល់ដល់ភាពសុច្ចរឹត រឺឯករាជភាពរបស់ខ្លួន។
- បញ្ចូលទស្សនៈផ្ទាល់ខ្លួនទៅក្នុងអត្ថបទដំណឹង ។ ~~(Cambodian#6)~~
- បដិសេធធ្វើការផ្សាយកែតម្រូវនៅពេលដែលសុពលភាពនៃភាពមិនត្រឹមត្រូវនៃដំណឹង ត្រូវបានរកឃើញដោយបុគ្គលិក ឬ បានទទួលតាមរយៈការស្តីបន្ទោសពីសំណាក់អ្នកស្តាប់ ។ ~~(Cambodian#10)~~

## **ឯករាជ្យ**

អ្នកសារពត៌មានអាជីព វិទ្យុ និង ទូរទស្សន៍ ត្រូវការពារឯករាជភាពរបស់អ្នកកាសែត ឱ្យរួចផុតពីជនទាំងឡាយណាដែល ព្យាយាម ប៉ុនប៉ងជះឥទ្ធិពល រឺត្រួតត្រាលើខ្លឹមសារដំណឹង។

**អ្នកសារពត៌មានអាជីព វិទ្យុ និង ទូរទស្សន៍ គប្បី:**

- ប្រមូលនិងរាយការណ៍ដំណឹង ដោយគ្មានការភ័យខ្លាច និងតតាំងយ៉ាងមុះមុតទល់នឹងឥទ្ធិពលមិនសម ស្រប ពីសំណាក់ កំលាំង ណាមួយពីខាងក្រៅ ក្នុងនោះរួមមានអ្នកផ្សាយពាណិជ្ជកម្ម ប្រភពដំណឹង កម្មវត្ថុនៃដំណឹង បុគ្គលដែលមានអំណាច និង បណ្តា ក្រុមដែលមានផលប្រយោជន៍ពិសេស។
- តស៊ូប្រឆាំងនឹងជនទាំងឡាយណាដែលព្យាយាមទិញ រឺ ជះឥទ្ធិពលខាងនយោបាយទៅលើខ្លឹមសារដំណឹង រឺជនណាដែលព្យាយាម បំភិតបំភ័យអ្នកយកពត៌មាន និងផ្សាយពត៌មាន ។
- កំណត់ខ្លឹមសារដំណឹង ដោយឈរលើមូលដ្ឋាននៃការវិនិច្ឆ័យផ្នែកការងារនិពន្ធសុទ្ធសាធ ពោលគឺមិនមែន ដោយសារ តែឥទ្ធិពលពីខាងក្រៅឡើយ។
- តស៊ូទល់នឹងឥទ្ធិពលនៃផលប្រយោជន៍របស់ខ្លួនឯងផ្ទាល់ និងការគាបសង្កត់ពីក្រុមមិត្តភក្តិ ដែលអាចធ្វើឱ្យសាបរលាបដល់ ភារកិច្ចសារពត៌មាន និងសេវាសាធារណៈ។
- ទទួលស្គាល់ថា ការឧបត្ថម្ភដល់ដំណឹង ទោះជាក្នុងរូបភាពណាក៏ដោយ មិនត្រូវប្រើប្រាស់ដើម្បីកំណត់ រឹតត្បិត រឺក៏បំភ័ន្តដល់ ខ្លឹមសារដំណឹងឡើយ។
- បដិសេធ មិនអនុញ្ញាតឱ្យផលប្រយោជន៍នៃកម្មសិទ្ធិ រឺអ្នកគ្រប់គ្រង ជះឥទ្ធិពលលើការវិនិច្ឆ័យដំណឹង និងខ្លឹមសារដំណឹង ដោយមិនសមស្របនោះឡើយ។
- ការពារសិទ្ធិសារពត៌មានសេរី សម្រាប់អ្នកកាសែតគ្រប់រូប ដោយទទួលស្គាល់ថា ការចេញអាជ្ញាប័ណ្ណណាមួយ ទោះជា ខាងផ្នែកវិជ្ជាជីវៈក្តី ពីខាងរដ្ឋាភិបាលក្តី គឺជាការរំលោភលើសិទ្ធិមួយនេះ។

**ការទទួលខុសត្រូវ:**

អ្នកសារពត៌មានអាជីព វិទ្យុ និង ទូរទស្សន៍ ត្រូវទទួលសាល់ថា ខ្លួនមានការទទួលខុសត្រូវ នៅចំពោះមុខសាធារណជន វិជ្ជាជីវៈ និងខ្លួនឯងផ្ទាល់ នូវរាល់សកម្មភាពទាំងឡាយរបស់ខ្លួន។

**អ្នកសារពត៌មានអាជីព វិទ្យុ និង ទូរទស្សន៍ គប្បី:**

- លើកទឹកចិត្តយ៉ាងសកម្ម ដល់អ្នកសារពត៌មានទាំងអស់ និងនិយោជក ឱ្យប្រកាន់ខ្ជាប់ តាមស្តង់ដារទាំងនេះ។

- ឆ្លើយតបនឹងកង្វល់របស់សាធារណជន។ ស៊ើបអង្កេតបណ្តឹងតវ៉ា និងកែរតម្រូវកំហុសឆ្គងភ្លាមៗ ក្នុងលក្ខណៈស៊ីជម្រៅ ដូចជារបាយការណ៍ពត៌មាន ដើមដែរ។
- ពន្យល់បំភ្លឺដល់សាធារណជន អំពីដំណើរការការងារសារពត៌មាន ជាពិសេសគឺ នៅពេលណាដែល ការអនុវត្តន៍បានបង្កឱ្យមានជាបញ្ហា រឺទំនាស់អ្វីមួយ។
- ទទួលស្គាល់ថាអ្នកសារពត៌មានអាជីពវិទ្យុ និង ទូរទស្សន៍ ត្រូវបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយសីលធម៌ ។
- ចៀសវាងកុំបញ្ជា ឬ លើកទឹកចិត្តដល់សកម្មភាពទាំងឡាយណាដែលនឹងបង្ខំឱ្យនិយោជិកប្រព្រឹត្តនូវ អមពើរអសីលធម៌។
- ត្រូវយកចិត្តទុកដាក់ស្តាប់និយោជិកដែលលើកឡើងនូវការជំទាស់ខាងសីលធម៌ ហើយត្រូវបង្កើតបរិយាកាស មួយដែល លើទឹកចិត្ត និង ជំរុញឱ្យមានការជំទាស់និងការពិភាក្សាបែបនេះ ។
- ត្រូវស្វែងរកការគាំទ្រ និង ផ្តល់ឱ្យកាសបណ្តុះបណ្តាលដល់និយោជិកឱ្យចេះធ្វើការសំរេចចិត្តប្រកបដោយសីលធម៌ ។

នៅក្នុងការបំពេញនូវការទទួលខុសត្រូវរបស់ខ្លួន ចំពោះវិជ្ជាជិវៈសារពត៌មានតាមរលកធាតុអាកាស RTNDA បានបង្កើតក្រមនេះ ឡើងដើម្បីកំណត់បញ្ហាសំខាន់ៗ ដើម្បីទុកជាមគ្គុទេសក៏សំរាប់សមាជិកទាំងឡាយរបស់ខ្លួន ដើម្បីជួយសំរួលដល់ការស្វ័យត្រួតពិនិត្យ និង ដើម្បីជួយដល់ការជជែកដេញដោលនាពេលអនាគត ។

អនុម័តនៅក្នុងកម្មវិធីហ្វឹកហ្វឺនអ្នកសារពត៌មានកម្ពុជានៅ Bowling Green រដ្ឋ Kentucky នាថ្ងៃទី 29ខែឧសភា ឆ្នាំ 2002។